# មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម
# THE CENTER FOR SOCIAL DEVELOPMENT

## សេចក្តីប្រកាសព័ត៌មាន

សេចក្តីណែនាំដល់អ្នកបោះឆ្នោត គោរពដល់សេរីភាពក្នុងការបញ្ចេញមតិ និង ការប្រកួតប្រជែងគំនិត ។

ភ្នំពេញ, ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម មានសេចក្តីរីករាយ និងប្រកាសនូវ ដំណោះស្រាយរវាង ម.អ.ស. និង គណៈកម្មាធិការជាតិរៀបចំបោះឆ្នោត (គ.ជ.ប.) ហើយនឹងបោះពុម្ព សេចក្តីណែនាំដល់អ្នកបោះឆ្នោតចំនួន ៩៧០,៣៦០ច្បាប់ សំរាប់ការបោះឆ្នោតឃុំសង្កាត់ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៧ ។

សេចក្តីណែនាំដល់អ្នកបោះឆ្នោតរបស់ **ម.អ.ស.** ផ្តល់ឱ្យប្រជាពលរដ្ឋខ្មែរ នូវព័ត៌មានសំខាន់ៗទាក់ទិនទៅនឹងការបោះឆ្នោតឃុំ សង្កាត់ ខាងមុខនេះ ។ ព័ត៌មានទាំងនេះ រួមមាន ៖ សិទ្ធិរបស់ប្រជាពលរដ្ឋម្នាក់ៗ បទបញ្ជា នីតិវិធី ហើយនិងឈ្មោះអ្នកដឹកនាំ ព្រមទាំងកម្មវិធីនយោបាយរបស់គណបក្សនយោបាយទាំង១២ ដែលប្រកួតប្រជែង ក្នុងការបោះឆ្នោតខាងមុខនេះ ដើម្បីឱ្យអ្នកបោះឆ្នោតម្នាក់ៗមានព័ត៌មានច្រើន ក្នុងការសំរេចជ្រើសរើសតំណាងរបស់ខ្លួន ។ **ម.អ.ស.** បានជឿជាក់យ៉ាងខ្លាំងថាព័ត៌មានដល់អ្នកបោះឆ្នោត ដោយសេរី ត្រឹមត្រូវ នៅក្នុងការបោះឆ្នោតមួយលើកៗ គឺជាចំណោទដ៏សំខាន់នៃលិទ្ធិប្រជាធិបតេយ្យ ។

នៅក្នុងសំបុត្រចុះ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៧ គ.ជ.ប. បានសុំឱ្យ **ម.អ.ស.** លុបឃ្លាមួយរបស់គណបក្សរណសិរ្សសង្គមជាតិនិយម ។

**ម.អ.ស.** យល់ឃើញថា មានការលំបាកដ៏សមៀម ដើម្បីឆ្លើយតបទៅនឹងសំណើនោះ ដែលមានមូលហេតុចំបងពីរ ៖

- ទីមួយ **ម.អ.ស.** បានជឿជាក់ថា សេរីភាពក្នុងការបញ្ចេញមតិ (ជាពិសេសសេរីភាពរបស់គណបក្សនយោបាយនៅក្នុងពេលបោះឆ្នោត) ហើយនិង ការប្រកួតប្រជែងគំនិត ។ សំណើរបស់ គ.ជ.ប. គឺវាផ្ទុយទៅនឹងគោលការណ៍លិទ្ធប្រជាធិបតេយ្យ ។

- ទីពីរ សំណើរបស់ គ.ជ.ប. ខុសទំនងពី **ម.អ.ស.** បានជឿទៅលើសិទ្ធិនៃការបោះពុម្ព កែប្រែ ឬបន្ថែមទៅលើកម្មវិធីនយោបាយគណបក្សណាមួយ ។ រឿងនេះមិនជាបញ្ហា ថាតើ **ម.អ.ស.** យល់ព្រម ឬមិនយល់ព្រមទេ អំពីសេចក្តីថ្លែងការរបស់ គ.ជ.ប. ។ **ម.អ.ស.** ជឿថានេះ ជាខ្លឹមសារនៃកម្មវិធីនយោបាយរបស់គណបក្សនីមួយៗ ។ សេចក្តីថ្លែងការនេះវាមិនមែនជាបញ្ហានៅក្នុងដំណើរការទាំងអស់នេះទេ ។ **ម.អ.ស.** គ្រាន់តែ ជាយាន្តតែប៉ុណ្ណោះ ហើយបំណងរបស់យើង គឺឱ្យប្រជាពលរដ្ឋមានព័ត៌មាន ។

នេះគឺជា ការបោះឆ្នោតឃុំ សង្កាត់ លើកទីពីរ នៅកម្ពុជា ហើយក៏ជាលើកទីពីរដែរ ដែល **ម.អ.ស.** បានផលិតសេចក្តីណែនាំដល់អ្នកបោះឆ្នោត ដើម្បីឱ្យព័ត៌មានទៅដល់ប្រជាពលរដ្ឋ ។ មូលនិធិសំរាប់ការបោះពុម្ព និង សកម្មភាពរបស់សេចក្តីណែនាំដល់អ្នកបោះឆ្នោត គឺត្រូវបានផ្តល់ឱ្យយ៉ាងទូលាយ ដោយស្ថានទូតជប៉ុន អង្គការ Diakonia ហើយនិង មូលនិធិអាស៊ី ។


ព័ត៌មានបន្ថែមសូមទាក់ទង ៖

- កញ្ញា **សេខ ឆារី** នាយិកាប្រតិបត្តិ ០១២ ២២២ ៥៥២
- លោកបណ្ឌិត **ហ្វ្រេង់សួរ អ៊ឹម** ប្រធានអង្គភាពបោះឆ្នោត និង សភា ០១២ ៣៧៦ ៣០១